# ការសំភាសន៍របស់អ្នកមីង ជីម ស្រីពៅ

**ក៖ អ្នកសំភាសន៍៖ រិទ្ធ ស៊ុនតានិច          ខ៖ អ្នកដែលត្រូវគេសំភាសន៍៖ ជីម ស្រីពៅ**

**គ៖ លី ស្រីរ៉ា ជាកូនស្រីរបស់អ្នកមីង**

## សង្ខេបរបស់អ្នកមីង ជីម ស្រីពៅ

អ្នកមីង ជីម ស្រីពៅគឺជាក្មេងកំព្រាឪពុកតាំងពីគាត់នៅក្នុងផ្ទៃម្តាយបាន៣ខែដោយសារឪពុក របស់គាត់បានស្លាប់ចោល។ក្រុមគ្រួសាររបស់គាត់គឺមានជីវភាពលំបាក ហើយពេលគាត់រៀប ការហើយក៏នៅតែមានភាពលំបាក ហើយគាត់បានផ្លាស់ទីលំនៅមកនៅទីរួមខេត្តសៀមរាប ទាំង២នាក់ប្តីប្រពន្ធ ហើយរស់នៅជាមួយម្តាយមីងគាត់ហើយជាអកុសលគឺថាផ្ទះរបស់ម្តាយមី ងរបស់គាត់បានត្រូវភ្លើងឆេះ ហើយរួចទាំងបងប្អូនជីដូនមួយរបស់គាត់បានស្លាប់នៅក្នុងភ្លើង នោះផងដែរហើយគាត់គ្មានសេសសល់អ្វីទេ។ ជីវិតរបស់គាត់ជួបនឹងរឿងរ៉ាវដល់សែនលំបាក ហើយគាត់បានប្រាប់ថាតាមរយៈព្រះយេស៊ូវគ្រីស្ទទើបធ្វើអោយគាត់មានភាពល្អប្រសើរខ្លះនៅ ក្នុងជីវិត ហើយគាត់មានកូន៦នាក់នៅក្នុងសព្វថ្ងៃនេះ។

ក៖ អូខេចាំចឹងថ្ងៃនេះខ្ញុំសូមអរគុណដល់អ្នកមីងដែលបានផ្តល់ពេលវេលាដ៏មានតំលៃដើម្បីខ្ញុំអាចចូលរួចសំភាសន៍អ្នកមីងនៅក្នុងថ្ងៃនេះចឹងហាំ! ហើយខ្ញុំដឹងថាការងារសំភាសន៍មួយនេះវាមិនមែនជាការងារធម្មតាតែវាតែជាកិច្ចការមួយដើម្បីជួយអោយក្រុមគ្រួសារអ្នកមីងក៏ដូចជាកូនចៅៗអ្នកមីងជំនាន់ក្រោយក៏អាចរក្សាប្រវត្តិរបស់អ្នកមីងបានហើយមួយទៀតវានឹងបង្រៀនអំពីភាពជូរចត់ទុក្ខលំបាកភាពសប្បាយរីករាយរបស់អ្នកមីងតាំងពីរជីវិតអ្នកមីងកើតរហូតមកដល់សព្វថ្ងៃពីការជួបប្រទះដែលអ្នកមីងតែងមានហើយអ្វីខ្លះដែលជាដំណោះស្រាយដែលអ្នកមី ងតែងតែដោះស្រាយ ដែលអ្នកមីងតែងតែជំនះនូវរាល់អ្វីៗទាំងអស់ដែលមានចឹងហាមីង! ហើយការសំភាសន៍ថ្ងៃនេះ គឺត្រូវបានបង្កើតឡើងដោយសកលវិទ្យាល័យមួយនៅក្នុងសហរដ្ឋអា មេរិចដែលគេហៅកាត់ថា ប៊ី វ៉ាយ យូ ចឹងឈ្មោះពេញរបស់វាគឺព្រីហ្គាំងយ៉ាង យូនីវើរស៊ីតធីចឹងគេបង្កើតឡើងដើម្បីជួយប្រជាជនខ្មែរយើងអោយមានរក្សាប្រវត្តិដូចដែលញ៉ុមនិយាយពីដើមចឹងហាំ! ចឹងការសំភាសន៍ធ្វើឡើងនៅក្នុងថ្ងៃទី២៤ ខែ០៤ ឆ្នាំ២០១៧។ហើយសំភាសន៍

ដោយខ្ញុំផ្ទាល់ រិទ្ធ ស៊ុនភានិចនឹងកូនអ្នកមីងដែរ ថ្ងៃនេះគាត់ចូលរួមដែរចឹងជំរាបឈ្មោះមួយមើលឈ្មោះអី?

គ៖ ញុំមឈ្មោះលី ស្រីរ៉ា។

ក៖ ចាំចឹងថ្ងៃនេះស្រីរ៉ាគាត់ចូលរួមសំភាសន៍ជាមួយខ្ញុំដែរ។ចឹងអ្នកមីងអ្នកមីងអាចជំរាបឈ្មោះអ្នកមីងហាំ?

ខ៖ ញ៉ុមឈ្មោះ ជីម ស្រីពៅ។

ក៖ ជីម ស្រីពៅ!

ខ៖ ចាំ!

ក៖ ចឹងកូនអ្នកមីងគាត់នឹងសួរខ្លះៗអំពីឈ្មោះរបស់អ្នកមីងដូចជាទាក់ទ ងទៅនឹងអាយុអ្នកមីងផ្ទាល់។

គ៖ តើម៉ាក់មានឈ្មោះហៅក្រៅអ្វីខ្លះ?

ក៖ មីងមានឈ្មោះហៅក្រៅទេ?

ខ៖ ញ៉ុមឈ្មោះតែហ្នឹងឯង។

ក៖ ឈ្មោះតែស្រីពៅ។

ខ៖ បើញ៉ុមដាក់អើក្នុងបញ្ជីវាផ្សេង បញ្ជីគ្រួសារគឺឈ្មោះផ្សេងដល់ពេលខាងក្រៅហៅនេះវាស្រួលហៅជាង ហៅស្រីពៅស្រួលហៅជាង។

ក៖ ឈ្មោះក្នុងបញ្ជីគ្រួសារឈ្មោះអ្វីដែរអ្នកមីង?

ខ៖ ជីម សុភី។

ក៖ ជីម សុភី!

ខ៖ ចាំ!

ក៖ អូខេចាំ! ចឹងបន្ត!

គ៖ តើម៉ាក់កើតនៅក្នុងឆ្នាំណា?

ខ៖ កើតនៅឆ្នាំ១៩៨២។

ក៖ អូខេ១៩៨២។

គ៖ តើកើតឆ្នាំចន្ទគតិកើតឆ្នាំមួយណាដែរ?

ក៖ មានន័យថាឆ្នាំចន្ទ័គតិ ឆ្នាំខ្មែររបស់យើងហាអ្នកមីង?

ខ៖ ឆ្នាំខ្មែរ!

ក៖ ឆ្នាំជូត ឆ្លូវអីហាំ?

ខ៖ ច។

ក៖ ឆ្នាំច! អូខេ! ចឹងសំរាប់ថ្ងៃខែអ្នកមីងចាំទេ?ថ្ងៃខែហា?

ខ៖ ខែ០៩។

ក៖ ចាំ!

ខ៖ ថ្ងៃទី២៧។

ក៖ ចាំចាំ!

ខ៖ ចំថ្ងៃពុធ។

គ៖ តើម៉ាក់កើតនៅកន្លែងណា?

ខ៖ នៅភូមិជ្រៃខាងជើង។

ក៖ ភូមជ្រៃខាងជើង?

ខ៖ ចាំ!

គ៖ នៅក្នុងខេត្តណាដែរ?

ខ៖ ខេត្តសៀមរាប។

ក៖ ខេត្តសៀមរាបយើង។ហើយចុះនៅក្នុងភូមិឃុំអីដែរអ្នកមីង?

ខ៖ អើឃុំគែសង្កែ ស្រុកសូត្រនិគម។

ក៖ អ្នកមីងជាអ្នកស្រុកសូត្រនិគម!

ខ៖ ចាំ!

គ៖ តើម៉ាក់មានបងប្អូនចំនួនប៉ុន្មាននាក់?

ខ៖ ៥នាក់។

គ៖ តើម៉ាក់ជាកូនទីប៉ុន្មាននៅក្នុងគ្រួសារ?

ខ៖ ៧ កូនទី៥។

ក៖ កូន៧គេ!

គ៖ តើបងប្អូនរបស់អ្នកមានឈ្មោះអ្វីខ្លះ?

ខ៖ មានឈ្មោះអើ ជីម ផល្លា ជីមផល្លាទី២ ជីម សុផៃទី៣ ជីម ផល្លីទី៤។

ក៖ ហើយបន្ទាប់មកអ្នកមីង?

ខ៖ ចាំ!

ក៖ ចុះទី១អ្នកណាគេ?

ខ៖ ទី១ជីម សុផល។

ក៖ ជីមសុផល។

ខ៖ ចាំ!

កៈ ចឹងសំរាប់អ្នកមីងអ្នកមីងចងចាំអំពីរឿងរ៉ាវនៅពីក្មេងៗជាមួយពួក គាត់ទេ?

ខៈ ហ៊ីចាំ ចាំបានខ្លះៗ។

កៈ ហ្នឹងហើយ ជំរាបអាខ្លះៗហ្នឹងមក!

ខៈ ចាំថាត្រង់យើងនៅពីទូចយើងហូបលំបាក ព្រោះយើងអត់មានប៉ាហ្ន៎! ប៉ាញ៉ុមស្លាប់តាំងពីញ៉ុមនៅក្នុងពោះ៣ខែ។

កៈ ចា៎!

ខៈ ពេលនឹកឃើញអញ្ចឹងនិយាយអត់ចង់ចេញ ជីវិតលំបាក ពេលខល្លះម៉ែញ៉ូមគាត់រកអត់បានអញ្ចេះទៅគាត់បបរ បបរធាងត្រាវហើយគាត់បុកគល់ស្លឹក គ្រៃ។

កៈ ចា៎!

ខៈ គាត់បុកធ្វើអាបបរផេកហ្នឹងបង! ពីបងប្អូនហូបទៅ ណាមួយគាត់នៅជាមួយ យាយ ហើយយាយនោះក៏គាត់អត់មានតាដែរ តាស្លាប់ គាត់ចិញ្ចឹមពួកញ៉ុមបងញ៉ុមទៅរកខ្លះ ទៅបានខ្លះទៅ ញ៉ុមចាំបានតែត្រង់ហ្នឹងគាត់បបរគាត់អីទៅញ៉ុមនឹកឃើញមកដល់សព្វថ្ងៃរហូ តដល់ពេលញ៉ុមបានរៀងត្រើសប៉ុនកូនញ៉ុមនេះឯង ញ៉ុមនៅជាមួយអ៊ំញ៉ុម នៅទៅអ៊ំញ៉ុមគាត់ ទៅស្រូវគាត់អោយស្រូវ២កញ្ជើរយកមកកិន ហើយនឹងដោះស្រាយជីវភាពមិនបានគ្រប់គ្រាន់ ទេនៅតែលំបាកហើយញ៉ុមចេះឡើងដើមឈើដើមអីតាំងពីតូច ដកព្រលិតដកអីជួយម៉ែញ៉ុម ដើម្បីបងញ៉ុមអីក៏គាត់នេះដែរគាត់ជួយបងញ៉ុមគាត់ដកព្រលិតទៅម៉ែញ៉ុមក៏បេះផ្កាកំប្លោកទៅ ញ៉ុមអត់ចេះជិះកង់ទេ គាត់ចេះតែដើរយកទៅលក់នៅឯផ្សារថ្នល់ចែកនោះ គាត់យកទៅលក់ ហើយបានមកហើយបេះអំពិលបេះអីយកទៅលក់ដែរប្រហែលបានតិចតួចមកទិញអង្ករ ហើ យគាត់ទិញត្រីមកគាត់ហូបដល់ល្ងាចទៀត និយាយៗទៅវាពិបាកជូរចត់ច្រើនណាស់!

កៈ ចា៎! ចឹងសំរាប់អ្នកមីងតើឥឡូវពួកគាត់រស់នៅឯណាខ្លះ?

ខៈ គាត់បែកអស់ហើយគាត់មានក្រុមគ្រួសារប៉ុន្តែក្រដែរ គាត់ក្រលំបាកគាត់នៅស្រុកគេហើយ នៅស្រុកគេនោះក៏គ្មានដីគ្មានផ្លីដែរនៅតែចាំដីអោយ សុទ្ធតែ ចាំដីអោយគេអត់មានប្រាក់ខែ ប្រាក់អីនឹងគេទេ។

កៈ ចាំ!

ខៈ ដូចថាយើងរស់នៅមួយក្បាលស្រុកគេ ហើយឥឡូវគាត់ដើររើស គ្រាប់ស្វាយចន្ទីលក់ទៅ ១គីឡូតែ៥០០ទេ។

កៈ ចុះសំរាប់អ្នកមីងដូចជាបងប្អូនអ្នកមីងទាំងអស់តើអ្នកណាដូចជាទទួលបន្ទុកជួយក្រុមគ្រួសារអ្នកមីងហាំ?

ខៈ គាត់អត់មានបងប្អូនណាជួយគ្នាទេ! ហើយទឹមតែដល់ញ៉ុមមានប្តីពេល គាត់ តាមពិតវាពិបាកអញ្ចេកញ៉ុមកាលពេលនៅជំដែកញ៉ុមអត់មានការងារធ្វើទេដោយសារប្តីញ៉ុមទៅឃ្លាំងទៅអីទៅគាត់ទៅអូសត្រីជាមួយគេ១ខែតែ១៥០០០០។

កៈ ចាំ!

ខៈ ១ខែតែ១៥០០០០ យកមកហូបក៏ មិនគ្រប់មិនគ្រាន់ដល់ពេលគាត់លង់ទឹក គាត់ទៅអូសទៅលង់ទឹក ទៅគាត់ក៏ឈប់ទៅឯណោះ បានគាត់រត់មកនៅសៀមរាប ចេះតែកម្មមកហើយដល់ពេលយូរៗ គាត់ថាហ៊ីណែហូបតែឯង វាលំបាកហើយ ណាមួយវាបែកចែក២។

កៈ ចាំ!

ខៈ ដូចថាគាត់ផ្ញើរលុយមកញ៉ុមផងគាត់ហូប នៅទីណោះផង។

កៈ ចាំ!

ខៈ ចុះហើយគាត់ឌុបញ៉ុមនឹងឯង ឌុបញ៉ុមជាមួយកូនមកមកសៀមរា បហ្នឹងឯង មកសៀមរាបទៅធ្វើការសំណង់ ១ថ្ងៃតែ២៥០០ទេ។

កៈ ចាំពីមុនមែនទេមីង?

ខៈ ចាំ! ពីមុន២៥០០ទេរហូតដល់ពេលបានធ្វើយូរៗៗទៅបាន បានឡើងៗៗទៅបានញ៉ុមវាបានគ្រាន់កង់ថ្មីកង់អី ហើយដល់ពេលអា២០០៣នេះញ៉ុមនៅផ្លូវ៦០ជាមួយមីងហើយនៅជាមួយមីងនៅថ្ងៃណោះហ្នំ! ភ្លើងឆេះផ្ទះ។

កៈ ហ្នំ!

ខ៖ ភ្លើងឆេះផ្ទះហើយ កង់ថ្មីដែលទិញមកហើយដែរ នោះក៏អស់ខោអាវក៏អស់ លុយ២៥០០០ នោះក៏អស់ ហើយកូនមីងញ៉ុមងាប់២នាក់ទៀតឥឡូវ វេទនាជាងគេ។

ក៖ មូលហេតុអីបានឆេះអ្នកមីង?

ខ៖ ញ៉ុមវាអត់ដឹងដែរ ចាំមើលពេលព្រលឹមក្រោកតាំងពីម៉ោងយើងដាំបាយអោយគាត់ទៅធ្វើការ។

ក៖ ចាំ!

ខ៖ ដល់អោយគាត់ទៅធ្វើការទៅដល់ស្រាប់តែដល់ម៉ោង១២ឡើង ដល់ម៉ោង១២ នោះឯង ខ្យល់វាកួច ខ្យល់វាខួចឡើងមែនទែន! ខ្យល់ខួចៗៗដើមស្រល់ ស្រាប់តែវាឆេះ ឆេះអា ផ្ទះមីងញ៉ុមនឹងឯងហើយផ្ទះមីងញ៉ុមអាក្រោមគាត់បាំងអើស្លឹក ហើយលើគាត់ប្រក់តង់។

ក៖ ចាំ!

ខ៖ ហើយក្រោមផ្ទះមានសាំងមួយធុងទៀត ទៅមិនដឹងថាមូលហេតុអីបានវាមានភ្លើងចឹង ព្រោះអីភ្លើងពីព្រឹកយើងពន្លត់អស់ហើយ។

ក៖ ចាំ!

ខ៖ អត់ដឹងផង ដល់ពេលរួចក៏ឆេះនឹងឯង ញ៉ុមក៏ពន្លត់ បងញ៉ុមលើកកូនញ៉ុមមួយញ៉ុមលើកកូនញ៉ុមអាកូនញ៉ុមទី២ហ្នឹងមួយ ហើយឆេះកូ នមីងញ៉ុមដែលវានៅលើផ្ទះដែលវាដេកនៅក្នុងមុងហ្នំ! យកអត់បានហើយម៉ែញ៉ុមគាត់យកកូន បងញ៉ុមរលៀកដៃដល់សព្វថ្ងៃ វាតង់វាឆេះ ញ៉ុមនឹងឯងលំបាកអត់មានណាជួយទេ ប្តីញ៉ុមគាត់ គាត់ប្រឹងទៅធ្វើការធ្វើការ ក៏ចេះតែបួងសួងទៅគាត់ទឹមចូលសមាជិក ចេះតែបួងសួងយាយតា កុងម៉ាអីពេញវាលអោយជួយ ចេះអោយជួយរកស៊ី ហើយញ៉ុមអត់មានទឹកដោះអោយកូនអឹម ទៀត ដល់ញ៉ុមអោយប្តីញ៉ុមខ្ចីលុយថៅកែហ្នឹងឯង ខ្ចីលុយគេទំរាំបានដោះគោអោយកូន កូនវា យំអើយយំ ហើយយើងក៏អត់មានអង្ករហូបទៀត!

ក៖ ចាំ!

ខ៖ ពិបាកអត់មានអ្នកណាជួយអ្នក ណារួចទេ ដល់ពេលរួចទៅក៏អ្នកជិតខាងនៅដេកញ៉ុមអត់ចុះមួយថ្ងៃវាស់ល្ងាចយើងអត់មាន បាយហូបផង! ទៅក៏គេស្រណោះគេអោយអង្ករមួយកំប៉ុងមកញ៉ុមក៏បបរ។

ក៖ ចាំ!

ខ៖ ប្ដីញ៉ុមទៅ ធ្វើការអត់មានបាយហូបទៀតពេលល្ងាចឡើងដឹងទៅគេ ធ្វើការជាមួយគេអោយខ្ញុំ១០០០០ មក ១០០០០យើងទៅទិញអង្ករ អង្ករ៥គីឡូមក ទិញអង្ករ៥គីឡូមកក៏ដល់ហើយ អត់មានអីហូ បទៀតចុះឆេះអស់រលីងហើយមានអីមានតែខោអាវមួយចង្កេះដល់ហើយបានយូរទៅញ៉ុមទៅ រើសអេតចាយ ដាក់កូនពរកូនមួយចំហៀងដាក់ការ៉ុងមួយចំហៀងទៅរើសអេតចាយ។

ក៖ ពេលដែលទៅហ្នឹងកូនទីប៉ុន្មានដែរអ្នកមីង?

ខ៖ កូនទី២ហើយកូនអាបងនោះបាននៅជាមួយម៉ែញ៉ុមនឹងឯង ទៅរើសអេតចាយ ចង់ទៅរើសអេតចាយ បានក្នុងមួយព្រឹកញ៉ុមបាន២៥០០។

ក៖ ចាំ!

ខ៖ គ្រាន់សំរាប់យើងយកមកទិញបីចេង អីបន្តិចបន្តួចយកមកហូប។

ក៖ ហ្នឹងហើយ។

ខ៖ ដល់រំលងបានយូរៗទៅបានប្ដីញ៉ុមបានធ្វើការទៅបានទិញកង់ ទិញកង់នោះមិនមែនទិញកង់អ្នកត្រឹមត្រូវទៀត ដឹងវាយកមកពីណាទេ វាយកមកលក់អោយណៃ៨០០០ទិញបានអានោះឯងនឹងរហូត បានចេះតែរីកៗបានដល់ញ៉ុមអើសព្វថ្ងៃ ដល់សព្វថ្ងៃចេះតែមានបានបន្តិចបន្តួចយើងចេះតែសន្សំខ្លះៗមកហើយណាមួយយើងចេះតែបង្កើតកូនទៀត បង្កើតកូនកាន់តែច្រើនទៀត ។

ក៖ ចាំ!

ខ៖ ហើយប្ដីញ៉ុមគាត់ចេះតែប្រឹងហើយឥឡូវម៉ែញ៉ុមគាត់ចេះតែជួយបន្តិច បន្តួចផង មានអីជួយគាត់ជួយមើលកំលាំងកូនយើងនោះណាំ!

ក៖ ចាំ!

ខ៖ យើងចេះតែដើររកទំ រាំយើងកូនធំទៅយើង ដល់ហើយញ៉ុមបានហើយ រួចបានញ៉ុមដល់អើបងញ៉ុមគាត់អោយខ្ចី ខ្ចី លុយ២៥០ដុល្លារទិញម៉ូតូអាកញ្ចាស់ គេជិះ ជិះដល់ពេលញ៉ុម ជិះទៅបានរួចទៅបានលក់អា កញ្ចាស់វាចោលទិញកង់ថ្មីវិញវាខូចពេក ទិញកង់ថ្មីរហូតដល់ញ៉ុមបានអើដល់២០១៤ ២០១៤ ២០១៥នេះឯងញ៉ុមចេះទៅនឹងគេ ទៅខាងយេស៊ូវដែរប៉ុន្តែមិនមែនខាងសាសនាយើងនេះទេ!

ក៖ ចាំ!

ខ៖ ខាងគេផ្សេងទៅគេជួយតាំងពីរអង្ករតាំងពីអីគេជួយយើងមកប៉ុន្តែវាមិនបានទេតែ យើងអាចដោះស្រាយបានដោះស្រាយបានខ្លះៗ ។

ក៖ ចាំ!

ខ៖ ដល់រហូតដល់ពេលញ៉ុមទៅនឹង គេទៅ ទៅៗយូរៗទៅគេថាញ៉ុមខាតទៅដូចថាខានទៅមួយអាទិត្យអញ្ចេះដល់ពេលគេមកទៅ ដល់គេមានអង្ករមានអីទៅហៅយើងអោយទៅហាំ! ប៉ុន្តែអ្នកខ្លះហាំ គេថាយើងអញ្ចេក ថាយើ ងទៅពេលមានអំណោយបានយើងទៅ ថាចុះបើញ៉ុមអាលេងរវល់ បើថ្ងៃហ្នឹងប៉ះថ្ងៃទំនេរទៀត គេថាពេលមានអំណោយបានទៅ ពេលអត់អំណោយអត់ទៅទេ ទៅញ៉ុមថាញ៉ុមមានចង់បាន អំណោយទេ អត់ក៏អត់ទៅអោយបានញ៉ុមស្គាល់ព្រះ។

ក៖ ចាំ!

ខ៖ ដល់ពេលគេថាហ៊ីព្រះនៅតែ នឹងបបូរមាត់មាននៅហ្នឹងក្នុងចិត្តទេថាអញ្ចេកឯងថាអោយញ៉ុម ថ្ងៃក្រោយឡើងញ៉ុមមានអំ ណោយទៅញ៉ូមមិនដែលទៅទាល់តែអត់អំណោយ បានញ៉ុមទៅ ញ៉ុមទៅទៅក៏នៃទៅគេថា ច្រើនពេក ថាច្រើនពេកញ៉ុមឈប់ទៅ ទៅបងញ៉ុមបងឌីគាត់ថាទៅ ទៅនេះទៅ ពៅឯងទៅ នេះទៅគ្មានអ្នកណាសំដីអាក្រក់គ្មានអ្នកណាគេនេះទេគេរាប់យើង រាប់យើងអោយតែឃើញ យើងមានយើងក្រ ស្រលាញ់យើងទាំងអស់គ្នានឹងឯង។

ក៖ ចាំ!

ខ៖ ហើយទៅក៏ញ៉ុមថាញ៉ុមសួរ ប្ដីញ៉ុមសំរេចចិត្តក៏បានទៅទាំងអស់គ្នាស្រួលទៅក៏ប្ដីញ៉ុមថាឯងបែកទៅទៅមុនទៅ អីញ៉ុមរវល់ ហើយឃើញចេះតែញ៉ុមអសកម្មច្រើនដល់រួចញ៉ុមបានស្គាល់ព្រះឯណោះញ៉ុមឈប់ទៅណោះ ក៏ចេះទៅណា ព្រះអង្គប្រទានពរញ៉ុម រហូតដល់ញ៉ុមបានម៉ូតូមួយថែមម៉ូតូ២ ហើយសព្វថ្ងៃញ៉ុ មបានម៉ូតូ២ហើយញ៉ុមដូចថាធូរ!

ក៖ ជីវភាពផ្លាស់ប្ដូរពីមុន។

ខ៖ ចាំ! ខុសប្លែកពីមុនហើយញ៉ុមនៅតែពិបាកកូនតែមួយមុខទេ! យើងពិបាកតែប៉ុណ្ណឹងវាអត់ទៅព្រះវិហារលោមយ៉ាងណាក៏ ញ៉ុមពិបាកតែប៉ុណ្ណោះឯងបើភាពឈឺជូរចត់នោះវាច្រើនណាស់ញ៉ុមនិយាយវាមិនអស់ទេ។

ក៖ ចាំហ្នឹងហើយ។

ខ៖ មានរហូតមកដល់សព្វថ្ងៃ ហើយណាមួយញ៉ុមអសកម្មទៀត ពិបាករឿងកូនហើយអសកម្ម ច្រើន ល្បងអត់បានទៅ ហើយណាមួយប្ដីញ៉ុមគាត់រវល់ការងារញ៉ុមអត់ចង់ទៅវាអត់មានអ្នក ណាឌុបទៀតពិបាកអាយើងហើយទៅ ញ៉ុមដើរយូរៗវាគិតច្រើនពេកអារឿងកូនផងអារឿងដី ផ្ទះនោះផងទៅក៏ពិបាកច្រើន។

ក៖ ច្របូកច្របល់ច្រើននៅក្នុងគ្រួសារ។

ខ៖ អត់គេដោះស្រាយមិនចង់ចេញ។

ក៖ ដល់អញ្ចុះហើយបានញ៉ុមថាណៃអើដោយសារញ៉ុមនឹកឃើញទៅពេលញ៉ុមទៅព្រះវិហារថ្ងៃមុន មិនមែនប៉ុន្មានថ្ងៃមុនវាយូរគ្រាន់ដែរ ញ៉ុមទៅទៅដល់នឹងរបងព្រះវិហារហើយញ៉ុមដូចមានអ្នកនៅចាំញ៉ុមចឹងឯង ចាំញ៉ុមថាដូចជាលោកពុកដូចជាម្ដាយប៉ុន្តែញ៉ុមខ្លាចគាត់ តែគាត់កាន់។

ក៖ ចឹងតើម្ដាយអ្នកមីងគាត់ឈ្មោះអីដែរអ្នកមីង?

ខ៖ គាត់ឈ្មោះ សូរ ផាត។

ក៖ សូរ ផាត! ចុះឪពុករបស់អ្នកមីងវិញ?

ខ៖ ឈ្មោះ ឡែម ផុន។

កៈ ឡែម ផុន!

ខៈ ចាំ!

កៈ ពួកគាត់ទាំងពីរនៅរស់ទាំង២នាក់ទេអ្នកមីង?

ខៈ គាត់នៅរស់តែម៉ែញ៉ុមទេ!

កៈ ហ្អំចឹង!

ខៈ ពុកញ៉ុមគាត់ស្លាប់តាំងពីរពេលដែលញ៉ុមនៅក្នុងពោះ៣ខែ។

កៈ ចុះពួកគាត់ទាំង២រស់នៅក្នុងខេត្តឬក៏ភូមិឃុំស្រុកជាមួយអ្នកមីងឬក៏ម៉េចដែរ?

ខៈ ចាំ! នៅជាមួយគ្នានឹងឯង ហើយចុះឪពុកអ្នកមីងគាត់ធ្វើអ្វី! ហ្ហំសុំទោសគាត់ស្លាប់ហើយ។ ចុះចំនែកម្តាយអ្នកមីងគាត់ធ្វើអ្វីសំរាប់ចិញ្ចឹមជីវិតនៅពេលដែលអ្នកមីងនៅតូចៗក្នុងគ្រួសារ ?

ខៈ គាត់ធ្វើតែស្រែគាត់ដកស្ទូងតែចឹងឯងតែដល់ពេលគាត់ផុតពីដកស្ទូងទៅគាត់អើនៅដូចថា គាត់បេះបន្លែ បេះស្លឹកបាស បេះស្លឹកងប់អីហើយលក់ដើម្បីចិញ្ចឹមញ៉ុមតាំងពីទូចៗ។

កៈ ចាំ!

ខៈ ដល់ពេលញ៉ុមចេះជួយគាត់ ហើយគាត់អោយញ៉ុមរៀនដែរប៉ុន្តែណាមួយជីវិភាពយើងវា ពិបាក ទៅវាចេះតែជួយគាត់មក តែយើងរៀនវាមិនបានច្រើនទឹមតែថ្នាក់ទី៣ បងក៏ថ្នាក់ទី៣ ដែរ បាន អានបានតិចៗ។

កៈ ចុះអ្នកមីងស្គាល់ឈ្មោះតាយាយរបស់អ្នកមីងទេ?

ខៈ អើ តាអើឈ្មោះអើតាសូរ អានេះខាងម៉ែញ៉ុមហាំ!

កៈ ចាំ!

ខៈ យាយវន្ត័ អើយនឹងខាងឪពុក ញ៉ុមគាត់ឈ្មោះអីចេះតែភ្លេចឈ្មោះ គាត់ ស្គាល់តែយាយ យាយយុត។

កៈ ចាំ!

ខ៖ ហើយនឹងតា ជឹម។

ក៖ ចាំ! ហើយគ្រួសារអ្នកមីងក្រៅ នៅខេត្តសៀមរាបនឹងប្រទេសកម្ពុជាគាត់ទៅរស់នៅខាងខេត្តផ្សេងឬក៏ប្រទេសក្រៅទេមីង?

ខ៖ អត់ អត់ដែលទៅណាទេ នៅតែក្នុងស្រុក។

ក៖ ចាំ!

ខ៖ ក្នុងខេត្តនេះ។

ក៖ ហើយស្វាមីរបស់អ្នកមីងគាត់មានឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះ អ៊ូច រី។

ក៖ អ៊ូច រី?

ខ៖ ចាំ!

ក៖ ចាំ! គាត់អាយុប៉ុន្មានហើយពេលនេះ?

ខ៖ គាត់អាយុដំណាលនឹងញ៉ុមដែរ៣៧។

ក៖ ៣៧ដែរ។អូខេចឹងអ្នកមីងរៀបការនៅក្នុងឆ្នាំណាដែរអ្នកមីង?

ខ៖ ឆ្នាំ១៩៩៧។

ក៖ ៩៧(១៩៩៧) ពេលញ៉ុមកំពង់កើត។ចាំចឹងជាអាពាហ៍ពិពាហ៍ដែលបង្កើតឡើងដោយឪពុកម្តាយឬក៏ការសំរេចចិត្តរបស់អ្នកមីង?

ខ៖ យើងស្រលាញ់គ្នាដោយចិត្តឯង យើងអត់បានអើអត់បានម៉ែឪយើងផ្គត់ផ្គង់យើងអោយទេណាស់!

ក៖ ចាំចាំ!

ខ៖ យកគ្នាដោយចិត្តឯង។

កៈ ហើយពេលលោកពូស្ដីដណ្ដឹងអ្នកមីងតើថ្លៃជំនូនប៉ុន្មានដែរ?

ខៈ អើកាលណោះវាថោកដែរ យើងថាថោកចុះ ព្រោះសម័យនេះវាសម័យលុយដុល្លារ កាលណោះលុយតែ៩៥០០០០។

កៈ ៩៥០០០០ ១០០ដុល្លារជាងដែរអ្នកមីង។

ខៈ ១០០ជាង។

កៈ ចាំចឹងអើអ្នកមីងជួបលោកពូដំបូងនៅឯណាដែរពេល?

ខៈ ញ៉ុមធ្វើការអុសនៅជាមួយម៉ែញ៉ុមនៅអើព្រៃលើ យើងនៅស្រុកលើ។

កៈ ចាំជួបគាត់ទៅហើយក៏មានទំនាក់ទំនងជាមួយគ្នា ។

ខៈ តែយកហ្នឹងញ៉ុមក៏មិនបានទៅស្រលាញ់គាត់ដែរប៉ុន្តែគាត់នៅជាមួយម៉ែញ៉ុម គាត់នៅអារអុសជាមួយម៉ែញ៉ុមចឹងទៅក៏ ហើយគាត់ឈឺទៅក៏ញ៉ុមនេះបោកខោអាវអោយគាត់បណ្ដើរដាក់បណ្ដាសារអោយគាត់បណ្ដើរ កម្មពៀរ! មិនថាដាក់បណ្ដាសារអីគាត់ទេ មិនដឹងស្អីពោលគាត់ទេ ហើយភ្នែកគាត់អត់មានបើករួចឯណា ទៅខោអាវអីញ៉ុមអ្នកបោកបាយក៏ញ៉ុមអ្នកដាំ ហើយម៉ែញ៉ុមថាកូនអើ្ហយ បោកអោយទៅ យកតែបុណ្យទៅ ញ៉ុមថាហ៊ីកម្មពៀរញ៉ុមអ្នកបោកខោអាវអោយអ្នកដែលគាត់ស្រលាញ់ទេដែល គូរដណ្ដឹងគាត់ក៏មិនអោយបោកទៅ! គាត់មានគូរដណ្ដឹងប៉ុន្តែគូរដណ្ដឹងគាត់រត់យកប្ដីបាត់ហើយ។

កៈ ហ្អូចាំ!

ខៈ ហើយគាត់មានអ្នកស្រលាញ់ច្រើន ប៉ុន្តែគាត់មិនដឹងម៉េច ក៏ញ៉ុមថាអោយញ៉ុមបោកខោអាវអោយមិនបាច់តែជាតិណាទេ តែជាតិ នេះៗយកញ៉ុមធ្វើប្រពន្ធបំរើញ៉ុមម្ដង អញ្ចុះឯង ចេះតែដាក់ទៅក៏ពេលគាត់ថាមិនបានទៅយក ទេបើសំដីអាក្រក់ម្ល៉េះ។

កៈ ប៉ុន្តែចុងបញ្ចប់បានជាគូរនឹងគ្នា។

ខៈ ម៉ែញ៉ុមប្រាប់ថាតែអ្នកណាក្រឡុងជើងអ្នកណាអោបយើងអ្នកណាថើបយើងឆាប់យកធ្វើប្ដីអោយហើយទៅ ថាមិនដឹងអី ញ៉ុមមិនដឹងអី តែចាប់អោបញ៉ុមថើបញ៉ុមដឹងតែយកដឹងទៅថាម៉េចប្រាប់ថាចឹងបើអត់ដឹងមែននោះ។

កៈ កាលហ្នឹងសម័យអត់ស្ងួរជឿនលឿន។

ខៈ អត់ស្ងួរជឿនលឿន។

កៈ អ្នកមីងមានកូនប៉ុន្មានហើយ?

ខៈ សព្វថ្ងៃមានកូន៦នៅក្នុងពោះ។

កៈ គាត់មានឈ្មោះអីគេខ្លះដែរអ្នកមីង?

ខៈ អើ កូនទីឈ្មោះ រី សុខរុន កូនទី២ឈ្មោះ រី សុខរ៉ាន់ ទី៣ រី ស្រីរ៉ា ទី៤ រី វិសូរ ទី៥ រី វីហ្សា។ មួយទៀតមិនដឹងទេ មិនទាន់កើតអត់ទាន់ដាក់អោយហើយ។

កៈ ចាំ! ហើយអ្នកមីងក្រៅពីភាសាខ្មែរអ្នកមីងចេះភាសាអីផ្សេងទេ?

ខៈ អត់ចេះសោះ ខ្មែរអាណាមានជើងមានដៃទៀតអត់ចេះសោះ!

កៈ អ្នកមីងរៀនដល់ថ្នាក់ទីប៉ុន្មានដែរ?

ខៈ ទី៣ ។

កៈ ទី៣!

ខៈ ទី៣ហ្នឹងមិនដឹងចប់ផង។

កៈ ចុះអ្នកមីងចាំឈ្មោះសាលាហ្នឹងទេ?

ខៈ សាលាហ្នឹងសាលារៀនថ្នល់ចែក។

កៈ ថ្នល់ចែក!

ខៈ ចាំសាលាបឋមសិក្សាថ្នល់ចែក។

កៈ ហើយសំរាប់អ្នកមីង អ្នកមីងដែលធ្វើស្រែចំការទេ?

ខៈ ធ្វើ ធ្វើជាមួយម៉ែ ផុតពីស្រែយើងទៅចំការព្រោះអីខាងណោះ ម៉ែញុំមគាត់ទៅត្រួសជាមួយគេទៅគាត់បានទៅគាត់ទៅដាំដល់ខែចេត្រ ខែវស្សាគាត់ទៅដាំ។

កៈ ចុះការធ្វើស្ករត្នោត ស្ករអីអ្នកមីងចេះទេ?

ខៈ អត់ អត់ដែលធ្វើទេ។

កៈ អ្នកមីងចូលចិត្តម្ហូបអ្វីដែរ?

ខៈ ម្ហូបចូលចិត្តទាំងអស់អោយតែរបស់ខ្មែរ។

កៈ ហើយសំរាប់បទចំរៀងអ្នកមីងចូលចិត្តស្តាប់បទចំរៀងអ្វីដែរ?

ខៈ អើចូលចិត្តតែបទពីដើមពីដើមហ្នឹង ប៉ែន រ៉នអី។

កៈ អូខេហើយអើអ្នកមីង អ្នកមីងមានជំនាញផ្ទាល់ខ្លួនរបស់អ្នកមីងទេ?

ខៈ ញ៉ុមកាលពីមុនញ៉ុមបានដេរកាបូបដេរអី។

កៈ ចាំ!

ខៈ ដល់ពេលយើងមានពោះមានពង្សទៅ យើងខានដេរ។

កៈ ចាំ!

ខៈ ជំានាញវាមិនច្បាស់លាស់វាពិបាក។

កៈ ចាំហើយខ្ញុំដូចជាអត់មានអីសួរដល់អ្នកមីងច្រើនប៉ុន្តែខ្ញុំចង់លើកទឹកចិត្តអ្នកមីងនិយាយជាចុងក្រោយទៅកាន់កូនៗអ្នកមីងនៅក្នុងគេថតសំលេងមួយហ្នឹងហាំដោយសារគេថតសំលេងមួយហ្នឹងជាប្រយោជន៍សំរាប់ដល់ពេលពួកគាត់ស្តាប់ទៅពួកគាត់នឹងដឹងពីគោលបំណងរបស់អ្នកមីងថាចង់អោយពួកគាត់ធ្វើអ្វីខ្លះហើយចង់លើកទឹកចិត្តគាត់សំរាប់ការអនាគត់ ធ្វើអ្វីខ្លះចឹងហាំអ្នកមីង?

ខៈ ចាំចង់អោយអោយវារៀនបានពូកែកុំសូវដើរលេងបើវាធំៗហើយបើវាអ្នកដែលអត់រៀនហ្នឹងវាឈប់រៀនហើយហ្នឹងចង់អោយវាធ្វើការបានសង្ឃឹមហើយបើថាជំនាញអីអោយវាច្បាស់ជាជំនាញហ្នឹងកុំអោយវាចាប់អានេះក៏របូត ចាប់អានោះក៏របូត ធ្វើអោយយើងវាពិបាកក្នុងការរកស៊ី ព្រោះម៉ែឪគ្មានអីជួយទេ។

ក៖ ចាំ!

ខ៖ មានតែជំរុញកូនអោយកូនខំប្រឹងរៀន បើវាឈប់រៀន ហើយបើវាចាប់ជំនាញអីអោយវាដឹងថាជំនាញនោះ។

ក៖ ចាំ!

ខ៖ ថាចាប់អោយច្បាស់មានតែ ប៉ុណ្ណឹង។

ក៖ ហើយខ្ញុំមានតែប៉ុណ្ណឹងដូចគ្នាហើយខ្ញុំក៏សង្ឃឹមថាអ្វីដែលអ្នកមីងនិយាយមកដូចជាភាពទុក្ខលំបាកនិងជីវិតរបស់អ្នកមីងផ្ទាល់នៅតែអោយក្រុមគ្រួសារអ្នកមីងបន្តចង់អោយចងចាំពីបញ្ហារឿងរ៉ាវទាំងអស់ហ្នឹងដែលបានកើតឡើងហ្នឹង ហើយហ្នឹងហើយញ៉ុមសូមសួរសំណួរមួយចុងក្រោយនេះតើអ្នកមីងយល់ព្រមអោយខ្ញុំដាក់រូបថតនឹងបទសំភាសន៍នេះនៅក្នុងគេហទំព័ររបស់សកលវិទ្យាល័យព្រីហ្កាំងយ៉ាងរបស់យើងដែរឬទេ?

ខ៖ ដាក់បានអត់មានអីទេ។

ក៖ ចាំហើយខ្ញុំក៏អរគុណអ្នកមីងដូចគ្នាហើយចឹងហ្នឹងហើយខ្ញុំមានតែប៉ុណ្ណឹងការសំភាសន៍គឺត្រូវបានបញ្ចប់អរគុណច្រើនអ្នកមីង។

ខ៖ អរគុណចាំ៕